**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧២.០១៨.០៥៤.១.សហក

ថ្ងៃ ចន្ទ ៧រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៨

**ជម្រាបមក**
**លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា នៃបុគ្គលរាយការណ៍ទាំងអស់**

**កម្មវត្ថុ៖** ដីកាសម្រេចបង្គាប់ឲ្យបង្កកទ្រព្យសម្បត្តិ និងមូលនិធិរបស់បុគ្គលដែលមានឈ្មោះក្នុងបញ្ជីអាល់កៃដានិងតាលីបង់។

**យោង ៖**- ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧
- ប្រកាសលេខ ធ៧.០៨.០៨៩ ប្រ.ក. ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ប្រកាសលេខ ធ១២.០១០.២០៦ ប្រ.ក. ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា
- អនុក្រឹត្យស្តីពីការបង្កកទ្រព្យសម្បត្តិរបស់ភេរវករ និងអង្គការនានាចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨
- ដីកាលេខ ៤២៦ ម.ហ.ក/១៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ របស់មហាអយ្យការអមសាលាឧទ្ធរណ៍សម្រេចបង្គាប់ឲ្យបង្កកទ្រព្យសម្បត្តិ និងមូលនិធិ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក លោកស្រី អគ្គនាយក អគ្គនាយិកាទាំងអស់ជ្រាបថា កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ សាលាឧទ្ធរណ៍ធ្លាប់ចេញដីកាបង្គាប់ឲ្យបង្កកទ្រព្យរបស់បុគ្គលដែលមានឈ្មោះក្នុងបញ្ជីអាល់កៃដានិងតាលីបង់។ នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ សាលាឧទ្ធរណ៍បានចេញដីកាសារជាថ្មីឡើងវិញបង្គាប់ឲ្យបង្កកទ្រព្យសម្បត្តិនិងមូលនិធិរបស់បុគ្គលដែលមានឈ្មោះក្នុងបញ្ជីអាល់កៃដានិងតាលីបង់ដដែល ស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១២៦៧ (ដូចមានភ្ជាប់ជូនមកជាមួយ និងនៅក្នុងគេហទំព័រ www.nbc.org.kh/cafiu/links.html)។ ដើម្បីអនុវត្តដីកានេះឲ្យមានប្រសិទ្ធភាព សូម លោក/ លោកស្រី ពិនិត្យឡើងវិញនូវឯកសារកត់ត្រារបស់លោក/លោកស្រីដោយគ្មានបង្អង់ ដើម្បីកំណត់អត្តសញ្ញាណរាល់ទ្រព្យសម្បត្តិនិងមូលនិធិរបស់បុគ្គលទាំងនេះ។ ក្នុងករណីពិនិត្យឃើញមានទ្រព្យសម្បត្តិ និងមូលនិធិទាំងនេះ សូម លោក/លោកស្រី បញ្ជូនព័ត៌មាននេះមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា អនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា ទទួលនូវការរាប់អានអំពីខ្ញុំ។

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**
**អគ្គលេខាធិការ**

ស.ហ.ក

**សាយ សំអាត**